ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៧២៧ សហវ.ប្រក

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៦

# ប្រកាស
# ស្តីពី
# ការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើទំនិញនាំចូលមួយចំនួន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យក្រមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជាលេខ ៥៧ ក្រ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៤៤ សហវ.ប្រក.គរ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០០៤

ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ លើលិខិតលេខ ៦៨២៤ សហវ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការលើកទឹកចិត្តដល់ផលិតករក្នុងស្រុក

## សម្រេច :

**ប្រការ ១ :** ត្រូវបានកែសម្រួលអត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួន ដែលមានចែងនៅក្នុងតារាងពន្ធគយកម្ពុជាជាធរមាន ដូចខាងក្រោមនេះ ÷

ក. សូន្យភាគរយ ( 0 % ) សម្រាប់បណ្តាមុខទំនិញដែលមានទីតាំងរងដូចខាងក្រោមនេះ ÷

២៨០៦.១០.00, ២៨១៥.១១.00, ២៨១៥.១២.00, ២៨២៨.១០.00,
២៨៣៦.២០.00, ២៨៤៧.00.១០, ២៩១៥.២១.00, ២៩១៨.១៤.00,
៣២០៣.00.១០, ៣៨១៥.៩០.១០, ៣៨១៥.៩០.៩០, ៧៦០១.១០.00,
៧៦០១.២០.00, ៧៦០៦.១១.១០, ៧៦០៦.១១.៩០, ៧៦០៦.១២.១០,
៧៦០៦.១២.២០, ៧៦០៦.១២.៣១, ៧៦០៦.១២.៣៩, ៧៦០៦.១២.៤០,
៧៦០៦.១២.៩០, ៧៦០៦.៩១.១០, ៧៦០៦.៩១.២០, ៧៦០៦.៩១.៩០,
៧៦០៦.៩២.១០, ៧៦០៦.៩២.២០, ៧៦០៦.៩២.៣០, ៧៦០៦.៩២.៩០,
៧៩០១.១១.00, ៧៩០១.១២.00, ៧៩០១.២០.00, ៧៩០៥.00.១០,
និងទីតាំងរងលេខ ៧៩០៥.00.២០ ។

ខ. ដប់ប្រាំភាគរយ (១៥%) សម្រាប់បណ្តាមុខទំនិញដែលមានទីតាំងរង ដូចខាងក្រោមនេះ ÷

២១០៣.៩០.២០, ២១០៤.១០.៩០, ២៧០៧.៩៩.១០, និងទីតាំងរងលេខ ២៧០៧.៩៩.៩០ ។

**ប្រការ ២ :** ត្រូវបានកែសម្រួល អត្រាអាករពិសេស ប្រាំភាគរយ (៥%) លើមុខទំនិញនាំចូល ដែលមានប៉ែងនៅក្នុងតារាងពន្ធគយកម្ពុជាជាធរមាន និងដែលមានទីតាំងវង លេខ ៨៧១១.២០.១០ ។

**ប្រការ ៣ :** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ព្រមទាំងអង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចំពោះទំនិញ ប្រភេទដូចបានរៀបរាប់ខាងលើ ដែលបំពេញបែបបទចុះបញ្ជិកាប្រតិវេទន៍លំអិត ដើម្បីនាំចូលមកព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ នេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាបជាព័ត៌មាន "
- ទីចាត់ការគយ និងរដ្ឋាករ
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
  " ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត "
- ឯកសារ - កាលប្បវត្តិ